ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ស្ថានឯកអគ្គរាជទូតកម្ពុជា
ប្រចាំអូស្ត្រាលី

លេខ: 17/21/REC/CBR

# សេចក្តីជូនដំណឹង

ស្ថានទូតសូមជូនដំណឹងដល់បងប្អូនពលរដ្ឋខ្មែរទាំងអស់កំពង់រស់នៅ ឬស្នាក់នៅប្រទេសអូស្ត្រាលី និងនូវែលហ្សេឡង់ ជ្រាបថា ចំពោះសុពលភាព និងការពន្យារសុពលភាពលិខិតឆ្លងដែនធម្មតា (Normal Passport)៖

១. <u>សម្រាប់លិខិតឆ្លងដែនធម្មតាប្រភេទថ្មី</u>

- សម្រាប់មនុស្សពេញវ័យ/ចាស់ មានសុពលភាព ១០ ឆ្នាំ
- សម្រាប់ក្មេងអាយុ ៥ ឆ្នាំចុះក្រោម មានសុពលភាព ៥ ឆ្នាំ
  - ➢ លិខិតឆ្លងដែនប្រភេទថ្មីនេះ នៅពេលផុតសុពលភាព<u>ពុំអាចពន្យារបានទេ</u>។ តម្រូវធ្វើថ្មីនៅអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មនៃក្រសួងមហាផ្ទៃ។

២. <u>សម្រាប់លិខិតឆ្លងដែនធម្មតាប្រភេទចាស់</u>

- លិខិតឆ្លងដែននេះមានសុពលភាពសរុប ៧ ឆ្នាំ (ចេញដំបូងមានសុពលភាព ៣ ឆ្នាំ និងអាចបន្តសុពលភាពបានចំនួន ២ ដង ដោយម្តងបាន ២ ឆ្នាំ)។
- ស្ថានទូតនឹងជួយបន្តសុពលភាពជូនសម្រាប់រយៈពេលនៃការបន្តខាងលើនេះដោយពុំមានការបង់កម្រៃសេវាអ្វីទាំងអស់។
- លិខិតឆ្លងដែនដែលបានបន្តសុពលភាព<u>ចំនួន ២ ដងមកហើយ ពុំអាចបន្តសុពលភាពបានទៀតទេ</u>។ បងប្អូនត្រូវស្នើសុំធ្វើលិខិតឆ្លងដែនថ្មីនៅអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មនៃក្រសួងមហាផ្ទៃ ដោយស្ថានទូតនឹងជួយសម្របសម្រួល និងបញ្ជាក់លើឯកសារពាក់ព័ន្ធផ្សេងៗជូនឱ្យបានទាន់ពេលវេលា។

ក្នុងករណីមានចម្ងល់ ឬសាកសួរព័ត៌មានបន្ថែមផ្សេងៗ សូមទំនាក់ទំនងតាមអាសយដ្ឋាន Email: Cambodianembassy@ozemail.com.au ឬទូរស័ព្ទលេខ ០២ ៦២៧៣ ៨០៦៤ រៀងរាល់ម៉ោងធ្វើការ។

អាស្រ័យហេតុនេះ សូមបងប្អូនពលរដ្ឋខ្មែរទាំងអស់មេត្តាជ្រាបតាមការគួរ។

ថ្ងៃ ចន្ទ ៤ រោច ខែមាឃ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

កង់បេរ៉ា ថ្ងៃទី 01 ខែ កុម្ភៈ ឆ្នាំ២០២១

5 Canterbury Crescent Deakin ACT 2600, Tel: (02) 6273 5867 / 6273 8064, Fax: (02) 6273 1053
E-mail: Cambodianembassy@ozemail.com.au Website: www.embassyofcambodia.org.au